# ក្រសួងមុខងារសាធារណៈ
# សាលាភូមិន្ទរដ្ឋបាល

# រចនាសម្ព័ន្ធ ក្រសួង ស្ថាប័ន

បង្រៀនដោយ៖ លោក ប្រាក់ ប្រានីថា

ប្រធាននាយកដ្ឋាន ត្រួតពិនិត្យ និងវាយតម្លៃ

អគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ

ក្រសួងមុខងារសាធារណៈ

Tel: 012 79 94 79/ 015 79 94 79
Email: prakpranitha2014@gmail.com

**សាលាភូមិន្ទរដ្ឋបាល, ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០១៦**



# មាតិកា

១. សញ្ញាណទូទៅ

២. រាជរដ្ឋាភិបាល

- សមាសភាព
- តួនាទីរបស់រាជរដ្ឋាភិបាល

៣. ក្រសួង ស្ថាប័ន

- ចំនួនក្រសួងស្ថាប័ន
- ការដឹកនាំ និងការគ្រប់គ្រង
- រចនាសម្ព័ន្ធ ក្រសួង ស្ថាប័ន

៤. ការកំណត់រចនាសម្ព័ន្ធនៃក្រសួង ស្ថាប័នថ្នាក់ជាតិ

# ១. សញ្ញាណទូទៅ

- ការរៀបចំរចនាសម្ព័ន្ធរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមគោលការណ៍ឯកភាពជាតិមួយ
- ១៩៩៣-១៩៩៨ រាជរដ្ឋាភិបាលបានធ្វើសមាហរណកម្មភាគីនយោបាយទាំងអស់ ដែលជាហត្ថលេខីនៃកិច្ចព្រមព្រៀងក្រុងប៉ារីស រួមទាំងនិស្សិតសរុបចំនួនប្រហែល ២៥.០០០នាក់ ទៅក្នុងប្រព័ន្ធរដ្ឋបាលឯកភាពជាតិមួយក្នុងគោលដៅ៖
    - បញ្ចប់ទាំងស្រុងនូវសង្គ្រាមរ៉ាំរ៉ៃផ្ទៃក្នុង
    - ផ្តល់ការងារដល់និស្សិតដែលបានបញ្ចប់ការសិក្សាមកពីបរទេសដើម្បីរួមគ្នាស្តារនិងកសាងប្រទេសជាតិឡើងវិញ

# ១. សញ្ញាណទូទៅ (ត)

- ផ្អែកលើសុខសន្តិភាព សុវត្ថិភាព ស្ថេរភាពនយោបាយ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច ព្រមទាំងសមាហរណកម្មទៅក្នុងតំបន់ និងពិភពលោក ព្រះរាជាណាចក្រកម្ពុជាបានប្រកាសឲ្យប្រើ៖
  - ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាល ឃុំ-សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០០១
  - ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលទទួលបានការអនុម័តកាលពីថ្ងៃ ទី ០១ ខែ មេសា ឆ្នាំ២០០៨

# ១. សញ្ញាណទូទៅ (ត)

- រចនាសម្ព័ន្ធរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា ចែកចេញ២៥ រាជធានី ខេត្ត និង ១៦៤៦ ឃុំសង្កាត់
- ក្រសួង ស្ថាប័ន មានចំនួន ៣១ ក្រសួង ស្ថាប័ន (រួមបញ្ចូលទីស្តីការគណៈរដ្ឋមន្ត្រី និងអង្គភាពប្រឆាំងអំពើពុករលួយ)

# ២. រាជរដ្ឋាភិបាល


ព្រះមហាក្សត្រ
នីតិបញ្ញត្តិ
នីតិប្រតិបត្តិ
តុលាការ
រាជរដ្ឋាភិបាល
ក្រសួងស្ថាប័នថ្នាក់ជាតិ
ថ្នាក់ក្រោមជាតិ

# ២.១. សមាសភាពរាជរដ្ឋាភិបាល

- ប្រមុខរាជរដ្ឋាភិបាល(នាយករដ្ឋមន្ត្រី)
  - សម្តេចក្រឡាហោម(ប្រធានស្ថាប័ន)
  - ឧបនាយករដ្ឋមន្ត្រី(ប្រធានស្ថាប័ន)
  - ទេសរដ្ឋមន្ត្រី(ប្រធានស្ថាប័ន)
  - រដ្ឋមន្ត្រី (ប្រធានស្ថាប័ន)
  - រដ្ឋលេខាធិការ(ប្រធានស្ថាប័ន)

# ២.២ តួនាទីរបស់រាជរដ្ឋាភិបាល (ត)

- ជាអង្គការនីតិប្រតិបត្តិ មានភារកិច្ចកំណត់ និង អនុវត្តនយោបាយរបស់រដ្ឋស្របតាមគោលការណ៍ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ
- ត្រូវធានាការអនុវត្តន៍ច្បាប់ និង ដឹកនាំកិច្ចការទូទៅរបស់រដ្ឋ លើកលែងតែកិច្ចការណាដែលជាសមត្ថកិច្ចរបស់អង្គការនីតិបញ្ញត្តិ និងអង្គការតុលាការ
- ត្រូវគ្រប់គ្រង បញ្ជា ប្រើប្រាស់យោធា នគរបាល កម្លាំងប្រដាប់អាវុធ និងរដ្ឋបាលក្នុងការធ្វើសកម្មភាពរបស់ខ្លួន
- ត្រូវដឹកនាំកិច្ចការទូទៅរបស់រដ្ឋតាមកម្មវិធីនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ





# ២.២ តួនាទីរបស់រាជរដ្ឋាភិបាល

- រាជរដ្ឋាភិបាល ត្រូវទទួលខុសត្រូវ ចំពោះមុខសភាអំពីនយោបាយទូទៅ និងសកម្មភាពរបស់ខ្លួន
- សមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជារួមមាន៖ នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ
- នាយករដ្ឋមន្ត្រីជាប្រមុខរាជរដ្ឋាភិបាល មានភារកិច្ចទទួលខុសត្រូវរួមជាមួយសមាជិកទាំងឡាយនៃរាជរដ្ឋាភិបាល ចំពោះមុខសភាអំពីនយោបាយទូទៅ និងសកម្មភាពរបស់រាជរដ្ឋាភិបាល





# ៣. ក្រសួង ស្ថាប័ន

- ក្នុងការដឹកនាំ គ្រប់គ្រង និងអនុវត្តសកម្មភាពការងាររាជរដ្ឋាភិបាល មានស្ថាប័នមួយចំនួនដែលច្បាប់បានបង្កើតឡើងឲ្យឈ្មោះថា "ក្រសួង និងរដ្ឋលេខាធិការដ្ឋាន"
- ការបង្កើតក្រសួង និងរដ្ឋលេខាធិការដ្ឋាន ត្រូវធ្វើឡើងដោយច្បាប់
- ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ត្រូវកំណត់ដោយអនុក្រឹត្យ
- នៅក្នុងនីតិកាលទី៥នៃរដ្ឋសភា(២០១៣-២០១៨) ក្រសួងស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជាមានចំនួន៣១

# ៣.១ ចំនួន ក្រសួង ស្ថាប័ន

**រាជរដ្ឋាភិបាល**

- ក្រសួងស្ថាប័នថ្នាក់ជាតិ២៩
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អង្គភាពប្រឆាំងអំពើពុករលួយ

# ៣.១ ចំនួន ក្រសួង ស្ថាប័ន (ត)

- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងការបរទេសសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងរ៉ែ និងថាមពល
- ក្រសួងផែនការ

# ៣.១ ចំនួន ក្រសួង ស្ថាប័ន (ត)

- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងព័ត៌មាន
- ក្រសួងយុត្តិធម៌
- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសុខាភិបាល

# ៣.១ ចំនួន ក្រសួង ស្ថាប័ន (ត)

- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងទេសចរណ៍
- ក្រសួងធម្មការ និងសាសនា
- ក្រសួងកិច្ចការនារី
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងមុខងារសាធារណៈ
- ក្រសួងព្រះបរមរាជវាំង
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អង្គភាពប្រឆាំងអំពើពុករលួយ

# ៣.២ ការដឹកនាំ និងគ្រប់គ្រង ក្រសួង ស្ថាប័ន

- ក្រសួង ស្ថាប័ន និងរដ្ឋលេខាធិការដ្ឋានត្រូវដឹកនាំដោយ សមាជិករាជរដ្ឋាភិបាលដែល មានឋានៈជា៖
  - ឧបនាយករដ្ឋមន្ត្រី
  - ទេសរដ្ឋមន្ត្រី
  - រដ្ឋមន្ត្រី អមដោយសមាជិករាជរដ្ឋាភិបាលមួយ ចំនួនទៀតដែលមានឋានៈជារដ្ឋលេខាធិការ
- សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលដែលដឹកនាំ គ្រប់គ្រង ក្រសួង ស្ថាប័ន ឬរដ្ឋលេខាធិការដ្ឋាន ហៅថា <u>ប្រធានស្ថាប័ន</u>

# ៣.២ ការដឹកនាំ និងគ្រប់គ្រង ក្រសួង ស្ថាប័ន

- ប្រធានស្ថាប័ន ត្រូវដឹកនាំការងារក្នុង ស្ថាប័ន និងគ្រប់គ្រងបុគ្គលិក មន្ត្រីរាជការ ដែលជា ភ្នាក់ងាររដ្ឋបាលកណ្តាល និងរដ្ឋបាលមូលដ្ឋាននៅក្រោមឱវាទ
- ប្រធានស្ថាប័ន មានភារកិច្ច ដឹកនាំ គ្រប់គ្រង ស្ថាប័ន និងអង្គភាពចំណុះក្នុងក្របខណ្ឌសមត្ថកិច្ចដែលកំណត់ក្នុងច្បាប់
- ប្រធានស្ថាប័ន មានសិទ្ធិលើកសំណើតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចមន្ត្រី រាជការក្រោមឱវាទ តាមបែបនីតិវិធីជាធរមាន ហើយប្រធានស្ថាប័ន ក៏មានសិទ្ធិចេញប្រកាស និងសារាចរ

# ៣.៣ រចនាសម្ព័ន្ធ ក្រសួង ស្ថាប័ន



# ៣.៣ រចនាសម្ព័ន្ធ ក្រសួង ស្ថាប័ន



# ៣.៣.១ ក្រុមខុទ្ទកាល័យ

- ជាក្រុមមនុស្សដែលប្រធានស្ថាប័ន (ឧបនាយករដ្ឋមន្រ្តី ទេសរដ្ឋមន្រ្តី រដ្ឋមន្រ្តីរដ្ឋលេខាធិការ) ជ្រើសរើសដោយខ្លួនឯងតាមតម្រូវការដែលចង់បាន
- ជាសហការី ដែលប្រធានស្ថាប័នស្រលាញ់ ចូលចិត្ត ពេញចិត្ត និងជាពិសេស គឺជាមនុស្សដែលទុកចិត្តបំផុត

# ៣.៣.១ ក្រុមខុទ្ទកាល័យ

- ចំនួនសហការីប្រភេទក្របខ័ណ្ឌខុទ្ទកាល័យ មាន៖
  - ០៣ រូប ចំពោះប្រធានស្ថាប័ន ជាទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី
  - ០២ រូប ចំពោះរដ្ឋលេខាធិការប្រធានស្ថាប័ន
  - ០១ រូប ចំពោះរដ្ឋលេខាធិការអនុប្រធានស្ថាប័ន
- សហការីខាងលើមានបេសកកម្ម ក្នុងឋានៈ៖
  - ជាអ្នកនយោបាយ ផ្អែកលើការងារក្នុងរង្វង់រាជរដ្ឋាភិបាល និងសភា
  - ជាអ្នករដ្ឋបាល ផ្អែកលើការងារ ផ្ទៃក្នុងក្រសួង ឬរដ្ឋលេខាធិការដ្ឋានរបស់ខ្លួន

# ៣.៣.១ ក្រុមខុទ្ទកាល័យ

- ត្រូវបានរៀបចំតាមឋានានុក្រម ដោយឡែកមួយ គឺ៖
  - នាយកខុទ្ទកាល័យ ០១ រូប តែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីសាមី
  - នាយខុទ្ទកាល័យ ០១ រូប
  - សមាជិក ០១ រូប
- ក្រុមខុទ្ទកាល័យ មានតួនាទី ភារកិច្ច មានជាអាទិ៍៖
  - **បំពេញមុខងារជាអ្នកនយោបាយ** លើ:
    - កិច្ចការរ៉ាប់រងទំនាក់ទំនងជាមួយនឹងខុទ្ទកាល័យរបស់រដ្ឋមន្ត្រីផ្សេងទៀត
    - ទំនាក់ទំនងជាមួយអ្នកតំណាងរាស្ត្រ និងប្រព័ន្ធឃោសនាទាំងឡាយ

# ៣.៣.២ ក្រុមរដ្ឋបាលកណ្ដាល

- ក្រសួង ស្ថាប័ននីមួយៗ ត្រូវរៀបចំឲ្យមាននូវអគ្គនាយកដ្ឋាន នាយកដ្ឋាន ការិយាល័យ ជាដើម
- ការបង្កើតអគ្គនាយដ្ឋាន នាយកដ្ឋានត្រូវកំណត់ដោយអនុក្រឹត្យ
- ការបង្កើត ការិយាល័យ ត្រូវធ្វើឡើងដោយប្រកាសរបស់ប្រធានស្ថាប័នសាមី
- ការរៀបចំបង្កើតឲ្យមានអង្គភាពកណ្ដាល ដើម្បីបម្រើដល់ការដំណើរការប្រព្រឹត្តទៅជាប្រចាំថ្ងៃរបស់ក្រសួង ស្ថាប័ន

# ៣.៣.២ ក្រុមរដ្ឋបាលកណ្ដាល

## ក. អគ្គនាយកដ្ឋាន

- ត្រូវដឹកនាំដោយអគ្គនាយក០១ រូប ដែលតែងតាំងដោយព្រះរាជក្រឹត្យ យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល និងផ្អែកតាមសំណើរបស់ប្រធានស្ថាប័នសាមី
- ករណីចាំបាច់ គឺអាចមានអគ្គនាយករងជាជំនួយការ ហើយអគ្គនាយករង មានឋានៈសមមូលនឹងប្រធាននាយកដ្ឋានតែងតាំងដោយអនុក្រឹត្យ

# ៣.៣.២ ក្រុមរដ្ឋបាលកណ្ដាល

## ខ. នាយកដ្ឋាន

- ត្រូវដឹកនាំដោយប្រធាននាយកដ្ឋាន ០១រូប
- ក្នុងករណីពិសេស ប្រធាននាយកដ្ឋាន០១ អាចមានឋានៈ និងបុព្វសិទ្ធិជាអគ្គនាយក
- ជាគោលការណ៍ ប្រធាននាយកដ្ឋាន មានអនុប្រធាននាយកដ្ឋាន ១រូប  ឬច្រើនរូបជាជំនួយការ

# ៣.៣.២ ក្រុមរដ្ឋបាលកណ្ដាល

គ. ការិយាល័យ

- ត្រូវដឹកនាំដោយប្រធានការិយាល័យ ០១រូប ដែលមានអនុប្រធានការិយាល័យជាជំនួយការតាមការចាំបាច់
- ប្រធានការិយាល័យ ត្រូវតែងតាំងដោយប្រកាសរបស់ក្រសួងស្ថាប័ន សាមី

# ៣.៣.២ ក្រុមរដ្ឋបាលកណ្ដាល

- អគ្គនាយក ប្រធាននាយកដ្ឋាន ប្រធានការិយាល័យ ត្រូវទទួលខុសត្រូវចំពោះដំណើរ ការអង្គភាពរបស់ខ្លួន និងការអនុវត្តភារកិច្ចដែលថ្នាក់លើប្រគល់ឲ្យ
- មុខតំណែងខាងលើ ជាការលើកទឹកចិត្តតែងតាំងក្នុងចំណោមមន្ត្រីរាជការដែលមានក្នុងក្របខណ្ឌមុខងារសាធារណៈ
- មុខតំណែងនេះ ត្រូវមានលក្ខណៈសម្បត្តិ សុខភាព សាមគ្គីភាព សីលធម៌ តម្រិះវិជ្ជា សមត្ថភាពជំនាញ អតីតភាព ព្រមទាំងឋានន្តរស័ក្តិស្របតាម  លក្ខន្តិកៈដោយឡែកនៃអង្គមន្ត្រីនីមួយៗ

# ៣.៣.២ ក្រុមរដ្ឋបាលកណ្ដាល

អង្គមន្ត្រីនីមួយៗ មានដូចតទៅ៖

- អង្គមន្ត្រីគ្រប់គ្រងរដ្ឋបាល
- អង្គមន្ត្រីក្រមការ
- អង្គមន្ត្រីលេខាធិការរដ្ឋបាល
- អង្គមន្ត្រីក្រមការភ្នាក់ងាររដ្ឋបាល
- អង្គមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- អង្គមន្ត្រីបច្ចេកទេសមធ្យម
- អង្គមន្ត្រីបច្ចេកទេសបឋម
- អង្គមន្ត្រីភ្នាក់ងារបច្ចេកទេស
- អង្គមន្ត្រីអនុរក្សពន្ធនាគារ
- អង្គមន្ត្រីនគរបាលជាតិ
- អង្គមន្ត្រីការទូត
- អង្គមន្ត្រីក្រមការបរទេស
- អង្គមន្ត្រីគ្រូបង្រៀនកម្រិតឧត្ដម
- អង្គមន្ត្រីគ្រូបង្រៀនកម្រិតបឋម
- អង្គមន្ត្រីគ្រូបង្រៀនកម្រិតមូលដ្ឋាន
- អង្គមន្ត្រីសុខាភិបាលជាន់ខ្ពស់
- អង្គមន្ត្រីសុខាភិបាលមធ្យម
- អង្គមន្ត្រីសុខាភិបាលបឋម...

# ៣.៣.២ ក្រុមរដ្ឋបាលកណ្ដាល

- សុទ្ធតែជាអ្នកបច្ចេកទេស មានចំណេះដឹង កិច្ចការរដ្ឋបាល សម្រាប់ជួយដល់ដំណើរការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន
- ជាអ្នកធានាឲ្យរាជការមានស្ថេរភាព ទោះបីជាខាងនយោបាយអស្ថិរភាពក៏ដោយ
- ត្រូវបានចាត់ទុកជាសសរទ្រូងដ៏រឹងមាំរបស់ក្រសួង ស្ថាប័ន
- គ្រប់ប្រធានក្រសួង ស្ថាប័នទាំងអស់ មិនអាចដកក្រុមការងាររដ្ឋបាលកណ្ដាល ដោយមិនគោរពនីតិវិធីដែលមានចែងក្នុងច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការ ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាបានឡើយ

# ៣.៣.៣ ក្រុមអធិការកិច្ច

- ក្រសួង ស្ថាប័ននីមួយៗ ត្រូវរៀបចំឲ្យមានជា៖
  - អគ្គាធិការដ្ឋាន
  - អធិការដ្ឋាន
  - ការិយាល័យ
- ការបង្កើតអគ្គាធិការដ្ឋាន អធិការដ្ឋាន ត្រូវកំណត់ដោយអនុក្រឹត្យ
- ការបង្កើតការិយាល័យចំណុះឲ្យអធិការដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់ប្រធានស្ថាប័នសាមី

# ៣.៣.៣ ក្រុមអធិការកិច្ច

## ក. អគ្គាធិការដ្ឋាន

- ត្រូវដឹកនាំដោយអគ្គាធិការ០១រូប ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើ របស់ប្រមុខរាជរដ្ឋាភិបាល និងយោងតាមសំណើរបស់ប្រធានស្ថាប័នសាមី
- អគ្គាធិការ ត្រូវមានអគ្គាធិការរងជាជំនួយការ យោងតាមតម្រូវការចាំបាច់
- អគ្គាធិការ មានឋានៈសមមូលនឹងអគ្គនាយក ត្រូវកំណត់ដោយព្រះរាជក្រឹត្យ
- អគ្គាធិការរង មានឋានៈសមមូលនឹងប្រធាននាយកដ្ឋាន ដែលកំណត់ដោយអនុក្រឹត្យ
- អគ្គាធិការ ត្រូវបានតែងតាំងក្នុងចំណោម អធិការក្រសួង ដែលមានគុណសម្បត្តិ និងបទពិសោធន៍គ្រប់គ្រាន់ក្នុងកិច្ចការងារ

# ៣.៣.៣ ក្រុមអធិការកិច្ច

## ខ. អធិការដ្ឋាន

- ត្រូវបានដឹកនាំដោយអធិការ០១រូប នឹងអាចមានអធិការរង០១ ឬ០២រូបជាជំនួយការ ដោយយោងតាមតម្រូវការចាំបាច់
- អធិការ មានឋានៈសមមូលនឹងប្រធាននាយកដ្ឋាន ដែលកំណត់ដោយអនុក្រឹត្យ
- អធិការរង មានឋានៈសមមូលនឹងអនុប្រធាននាយកដ្ឋាន ដែលកំណត់ដោយប្រកាសរបស់ ក្រសួង
- អធិការ ត្រូវបានតែងតាំងក្នុងចំណោមមន្ត្រីរាជការនៃក្រសួងដែលខ្លួនធ្លាប់បម្រើការងារ យ៉ាងតិច០៥ឆ្នាំ ហើយជាមន្ត្រីទទួលខុសត្រូវខ្ពស់ ឬធ្លាប់មានតួនាទីសំខាន់

# ៣.៣.៣ ក្រុមអធិការកិច្ច

- មានមុខនាទីជាអ្នកតាមដាន និងត្រួតពិនិត្យលើសកម្មភាពទាំងឡាយរបស់មន្ត្រីរាជការតាំងពីថ្នាក់ជាតិ រហូតដល់ថ្នាក់ក្រោមជាតិ(ការផ្តល់សេវាសាធារណៈ)
- តាមដាន ត្រួតពិនិត្យទាំងផ្នែកបច្ចេកទេស និងទាំងផ្នែកហិរញ្ញវត្ថុ ក្នុងប្រយោជន៍ ដើម្បីឲ្យក្រសួង ស្ថាប័នដំណើរការបានល្អ
- ការត្រួតពិនិត្យ ត្រូវធ្វើឲ្យស្របតាមគោលការណ៍ច្បាប់ ស្របតាមទិសដៅ និងបទបញ្ជារបស់ប្រធានស្ថាប័ន
- ក្រុមការងារអធិការកិច្ច ត្រូវរាយការណ៍ជូនប្រធានស្ថាប័នអំពីដំណើរការនៃការអនុវត្តការងាររបស់ស្ថាប័នទាំងមូល

# ៣.៣.៤ ក្រុមសវនកម្មផ្ទៃក្នុង

- ត្រូវបង្កើតនៅតាមបណ្ដាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ
- ការរៀបចំ និងការប្រព្រឹត្តទៅនៃសនវកម្មផ្ទៃក្នុង គឺត្រូវកំណត់ដោយអនុក្រឹត្យ
- ការធ្វើសវនកម្មផ្ទៃក្នុង មានគោលដៅ ជួយដល់ផ្នែកនីមួយៗ នៃក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ ដើម្បីបំពេញការទទួលខុសត្រូវឲ្យមានប្រសិទ្ធភាព
- គោលដៅចម្បងនៃសវនកម្មផ្ទៃក្នុង គឺផ្ដល់ឲ្យក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈនូវការវិភាគ ការវាយតម្លៃ អនុសាសន៍ មតិយោបល់ និងព័ត៌មានទាក់ទងនឹងសកម្មភាពដែលបានត្រួត ពិនិត្យ និងពិនិត្យឡើងវិញ

# ៣.៣.៤ ក្រុមសវនកម្មផ្ទៃក្នុង

- ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ ទទួលសុខត្រូវលើការបង្កើត និងរក្សាឲ្យមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង
- សវនកម្មផ្ទៃក្នុងនៅតាមបណ្តាក្រសួង ស្ថាប័ន និង សហគ្រាសសាធារណៈ ត្រូវទទួលខុសត្រូវអនុវត្តមុខងារឯករាជ្យ អំពីកិច្ចប្រតិបត្តិការនៃការងារ និងវាយតម្លៃសកម្មភាពរបស់អង្គភាព ដើម្បីជាជំនួយសម្រាប់ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងក្រុមប្រឹក្សារបស់សហគ្រាសសាធារណៈ

# ៣.៣.៤ ក្រុមសវនកម្មផ្ទៃក្នុង

- តួនាទីរបស់សវនកម្មផ្ទៃក្នុង៖
  - ត្រូវវាយតម្លៃដោយឯករាជ្យនូវភាពសមស្រប គ្រប់គ្រាន់នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង
  - ផ្តល់នូវការធានាលើភាពគ្រប់គ្រាន់នៃប្រព័ន្ធត្រួតពិនិត្យដែលកំពុងមាន និងកំពុងដំណើរការទៅតាមគោលដៅ
  - ត្រូវរាយការណ៍ទៅប្រធានស្ថាប័ន និងសហគ្រាសសាធារណៈរបស់ខ្លួន
  - ផ្ញើរបាយការណ៍ និងសេចក្តីសន្និដ្ឋាននៃការធ្វើសវនកម្មនេះទៅឲ្យអាជ្ញាធរសវនកម្មជាតិ

# ៣.៣.៤ ក្រុមសវនកម្មផ្ទៃក្នុង

- សវនកម្ម មានមុខងារ និងការទទួលខុសត្រូវដូចខាងក្រោម៖
  - ពិនិត្យឡើងវិញលើមុខងារ សកម្មភាព កិច្ចប្រតិបត្តិការ និងកម្មវិធីរបស់អង្គភាពក្នុងការិយបរិច្ឆេទសមស្របរបស់ថ្នាក់ដឹកនាំ
  - ពិនិត្យឡើងវិញនូវភាពដែលអាចជឿទុកចិត្តបាន ភាពទាន់ពេលវេលា និង ភាពច្បាស់លាស់នៃព័ត៌មានហិរញ្ញវត្ថុ និងកិច្ចប្រតិបត្តិការ ព្រមទាំងវិធីសាស្រ្ត ដែលប្រើប្រាស់

# ៣.៣.៥ ក្រុមប្រឹក្សា

- ក្រុមទីប្រឹក្សា នៅព្រះរាជាណាចក្រកម្ពុជា ៖
  - មានលក្ខណៈជាអង្គការ
  - មានលក្ខណៈជាបុគ្គល ដែលនៅអមរាជរដ្ឋាភិបាល ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការជាប្រធានស្ថាប័ន ដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងផ្តល់យោបល់លើគម្រោងនានា មុននឹងដាក់ជូនរាជរដ្ឋាភិបាល ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការ ប្រធានស្ថាប័ន ដើម្បីធ្វើការពិនិត្យ និងសម្រេច

# ៣.៣.៦ មន្ទីរ

- រចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ស្ថិតនៅថ្នាក់ក្រោមជាតិ ហៅថា <u>មន្ទីរ</u>
- មន្ទីរនីមួយៗ ត្រូវរៀបចំឲ្យមានជារចនាសម្ព័ន្ធគ្រប់គ្រងដូចខាងក្រោម៖
  - ប្រធានមន្ទីរ
  - អនុប្រធានមន្ទីរ
  - ប្រធានការិយាល័យ
  - អនុប្រធានការិយាល័យ
  - អង្គភាពថ្នាក់ក្រោមការិយាល័យ
- ប្រធានមន្ទីរ មានឋានៈស្មើនឹងអនុប្រធាននាយកដ្ឋានថ្នាក់កណ្តាល

# ៣.៣.៦ មន្ទីរ

- រចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ស្ថិតនៅថ្នាក់ក្រោមជាតិ ហៅថា មន្ទីរ
- ក្រសួង ស្ថាប័ននានានៃរដ្ឋបាលថ្នាក់កណ្តាល ឬរដ្ឋបាលថ្នាក់ជាតិ គឺមានរចនាសម្ព័ន្ធ មន្ទីររបស់ខ្លួនតាមបណ្តារាជធានី ខេត្ត ដែល បង្កើតឡើងដើម្បី៖
  - ងាយស្រួលនៅក្នុងការបម្រើសេវាសាធារណៈដល់ប្រជាពលរដ្ឋដែលរស់នៅមូលដ្ឋានផ្ទាល់ឲ្យងាយស្រួលទទួលបានសេវាពីរដ្ឋ
  - សំដៅលើកកម្ពស់ប្រសិទ្ធភាពការងារ និងកម្រិតជីវភាពរស់នៅរបស់ប្រជា ពលរដ្ឋ

ឧទាហរណ៍: មន្ទីរសុខាភិបាល មន្ទីរអប់រំ មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរកសិកម្ម មន្ទីរសាធារណៈការ និងដឹកជញ្ជូន ជាដើម។ល។

# ៤. ការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័ន

នៅក្នុងការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័ន រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដូចខាងក្រោម៖

# ៤. ការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័ន

**មាត្រា៤ .-**

រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ មានដូចខាងក្រោម៖

- រចនាសម្ព័ន្ធគ្រប់គ្រងនិងថ្នាក់ប្រហាក់ប្រហែលរួមមាន៖
  - អគ្គលេខាធិការដ្ឋាន/អគ្គនាយកដ្ឋាន/អគ្គាធិការដ្ឋាន
  - នាយកដ្ឋាន/អធិការដ្ឋាន
  - ការិយាល័យ
  - អង្គភាពថ្នាក់ក្រោមការិយាល័យ។
- មុខតំណែងគ្រប់គ្រងនិងថ្នាក់ប្រហាក់ប្រហែលរួមមាន៖
  - អគ្គលេខាធិការ/អគ្គនាយក/អគ្គាធិការ
  - អគ្គលេខាធិការរង/អគ្គនាយករង/អគ្គាធិការរង
  - ប្រធាននាយកដ្ឋាន/អធិការនៃអធិការដ្ឋាន
  - អនុប្រធាននាយកដ្ឋាន/អធិការរង
  - ប្រធានការិយាល័យ
  - អនុប្រធានការិយាល័យ
  - មុខតំណែងថ្នាក់ក្រោមអនុប្រធានការិយាល័យ។/.

# ៤. ការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័ន

**មាត្រា៥ .-**

ការកំណត់រចនាសម្ព័ន្ធមុខតំណែងនិងចំនួនមុខតំណែងគ្រប់គ្រងក្នុងរចនាសម្ព័ន្ធនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវផ្អែកលើទំហំការងារ ថវិកា និងចំនួនបុគ្គលិករបស់ក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិនីមួយៗ ដោយចំនួននៃមុខតំណែងគ្រប់គ្រងកម្រិតអនុប្រធានឬថ្នាក់ប្រហាក់ប្រហែលត្រូវកំណត់ដូចខាងក្រោម៖

១- មុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ

- អគ្គលេខាធិការរង អគ្គនាយករង អគ្គាធិការរង ឬថ្នាក់ប្រហាក់ប្រហែល ត្រូវមានចំនួនយ៉ាងច្រើនបំផុត៥(ប្រាំ)រូប។ ក្នុងករណីមានតម្រូវការចាំបាច់នូវអគ្គលេខាធិការរង អគ្គនាយករង អគ្គាធិការរង ឬថ្នាក់ប្រហាក់ប្រហែល លើសពីចំនួនដែលបានកំណត់ ក្រសួង ស្ថាប័នសាមីត្រូវស្នើសុំការសម្រេចពីនាយករដ្ឋមន្ត្រី
- អនុប្រធាននាយកដ្ឋានឬថ្នាក់ប្រហាក់ប្រហែល ត្រូវមានចំនួនច្រើនបំផុតពី៣(បី)រូបទៅ៥(ប្រាំ)រូប
- អនុប្រធានការិយាល័យឬថ្នាក់ប្រហាក់ប្រហែល ត្រូវមានចំនួនច្រើនបំផុតពី២(ពីរ)រូបទៅ៤(បួន)រូប។

# ៤. ការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័ន

**មាត្រា១០ ._**

មន្ត្រីរាជការស៊ីវិលទាំងអស់ដែលកំពុងកាន់មុខតំណែងគ្រប់គ្រងនិងកំពុងបំពេញការងារនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវទទួលបានការបែងចែកនិងការកំណត់មុខងារនិងភារកិច្ចច្បាស់លាស់ ដើម្បីគាំទ្រដល់បេសកកម្មនិងមុខងាររបស់ក្រសួង ស្ថាប័ន។

ក្រសួង ស្ថាប័ន និងអង្គភាពទាំងឡាយនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដែលមិនមានធ្វើការបែងចែកនិងការកំណត់មុខងារនិងភារកិច្ចច្បាស់លាស់ដល់មន្ត្រីរាជការដែលកាន់មុខតំណែងគ្រប់គ្រងនិងមន្ត្រីរាជការដែលបំពេញការងារក្នុងក្រសួង ស្ថាប័ន និងអង្គភាពរបស់ខ្លួន មិនត្រូវបានអនុញ្ញាតឱ្យធ្វើការជ្រើសរើសមន្ត្រីរាជការក្របខណ្ឌថ្មី មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែតក្នុងឆ្នាំនីមួយៗឡើយ ទោះបីមានឥណទានថវិកាគ្រោងទុករួចក៏ដោយ។

# សូមអរគុណ!